# មន្ទីរកសិកម្មខេត្តកណ្ដាល

# ត្រប់




អាស័យដ្ឋានទំនាក់ទំនង: ផ្លូវលេខ ១០៣ (តាខ្មៅ)

ទំនាក់ទំនងទូរស័ព្ទ: (០២៣ ៩៨៣ ៤៦១)

(០១២ ៨២៤ ៤២៥)



ឧបត្ថម្ភដោយ: អង្គការទីទីអូប៊ី VVOB

vvob education for development

ឆ្នាំ ២០១០


# ដំណាំត្រប់

## ១-ស្ថានភាពទូទៅ

នៅប្រទេសកម្ពុជា ត្រប់ជាប្រភេទបន្លែមួយយ៉ាងសាម័ញ្ញ ដែលប្រជាជនគ្រប់គ្នាតែងតែប្រើប្រាស់ធ្វើជាបន្លែក្នុងជីវភាពប្រចាំថ្ងៃ។ គេអាចដាំដុះវាជាលក្ខណៈចំការធំៗ និងជាលក្ខណៈសួនបន្លែចំរុះនៅតាមគ្រួសារ។

## ២. បច្ចេកទេសដាំដុះ

### រដូវកាលដាំដុះ

-រដូវប្រាំង: គេចាប់ផ្ដើមសាបកូននៅខែតុលា ហើយដាំខែវិច្ឆិកា ប្រមូលផលខែមករា ដល់ ខែមិនា។

-រដូវវស្សា: គេអាចសាបនៅខែឧសភា និងដាំនៅខែមិថុនា ប្រមូលផលនៅខែសីហា និង ខែតុលា ពិសេសតំបន់ខ្ពង់រាប។

### ការជ្រើសរើសពូជ

- ពូជមានប្រភពច្បាស់លាស់ (ពូជបង្កាត់ Hybrid $F_1$ ឬពូជក្នុងស្រុក )
- ពូជធន់នឹងជំងឺ សត្វល្អិត
- គ្រាប់ពូជត្រូវមានសុខភាពល្អ
- មានអាយុកាលលូតលាស់ខ្លី
- សមស្របតាមតំបន់ដាំដុះ និងតំរូវការទីផ្សារ
- មានដំណុះចាប់ពី ៨៥-៩០%
- ចំនួនពូជប្រើក្នុង១ហិកតាពី ១៥០-២០០ក្រាម។

### ការរៀបចំដី

ត្រូវរាស់ប្រមូលស្មៅ កាកសំណល់ដំណាំចាស់ៗយកទៅដុត ឬយកចេញពីចំការ បន្ទាប់មកភ្ជួរហាលដីរយៈពេលពី ៥-៧ថ្ងៃ ដើម្បីឱ្យស្មៅងាប់ និងផ្ដាច់ជីវិតពពួកសត្វល្អិតចង្រៃផ្សេងៗនៅក្នុងដី។ ក្រោយមកទើបរាស់បំបែកដីឱ្យម៉ត់ និងក្បៀរដីអោយស្មើពី ៣-៤លើក និងលើករងកំពស់ ២៥-៣០ សង្ទីម៉ែត្រទទឹងរង ១២០ សង្ទីម៉ែត្រ បណ្ដោយរងតាមផ្ទៃដីជាក់ស្ដែង ។

### ការដាំដុះ

ក-ការសាបគ្រាប់: គ្រាប់ត្រប់តូចល្អិត សំប៉ែត សំបករឹងហើយក្រាស់ មុននឹងសាបគ្រាប់ពូជត្រូវយកមកសំអាតជាមុនសិន បន្ទាប់មកយកទៅហាលថ្ងៃរយៈពេល ១ ទៅ ២ ម៉ោង ក្រោយមកទៀត ត្រូវយកទៅត្រាំទឹកក្ដៅអ៊ុនៗ (ត្រាំគ្រាប់ពូជនៅក្នុងទឹកក្ដៅ ៥០អង្សាសេ ដោយលាយទឹកក្ដៅ ១ ទឹកត្រជាក់២) រយៈពេល ១៥-២០នាទី ។ រួចទើបទៅត្រាំទឹកត្រជាក់ធម្មតា ១យប់ បន្ទាប់មកយកទៅផ្អាប់ ២យប់ នៅពេលគ្រាប់ត្រប់ដុះពន្លកសៗ ដំបូងអាចយកទៅសាប ឬ ដាក់ក្នុងកន្ទោងបានហើយ ។

របៀបសាបគ្រាប់លើថ្នាលធម្មតា: ដំបូងត្រូវរកទីតាំងថ្នាលសាបគឺ ដីស្រឡះ ដីទូលស្រស់ទឹក មានជីជាតិល្អ បន្ទាប់មកត្រូវកាប់ហាលដីអោយស្ងួត ទើបលើករងអោយបានត្រឹមត្រូវ ដីលើករងត្រូវធ្វើយ៉ាងណាឱ្យម៉ត់ល្អក្បៀរ និងរាបស្មើទើបយកជីកំប៉ុស្តិ៍ក្នុងបរិមាណ ១៥តោន/ហិចតា បន្ទាប់មករាស់លប់ជីទាំងនោះអោយកប់ជ្រៅទៅក្នុងដី ។

ការសាបគ្រាប់ពូជៈ ត្រូវធ្វើឡើងជាបន្ទាន់ ដោយសាបឱ្យរង្វើលល្មម ក្រោយសាបហើយ ត្រូវរោយកំទេចចំបើងខ្លីៗពីលើតាមក្រោយ ដើម្បីការពារសំណើមដី បន្ទាប់មកស្រោចទឹកអោយជោគ។ ការស្រោចទឹក ដកស្មៅ និងជីបំប៉នត្រូវធ្វើឡើងជាប្រចាំ ដើម្បីឱ្យកូនដំណាំដុះលូតលាស់បានល្អ ក្រោយសាបរយៈពេលពី ២០-២៥ថ្ងៃ អាចដកយកទៅដាំបាន។

ខ-ការដាំដុះ បន្ទាប់ពីលើករងរួច ត្រូវកាប់រណ្ដៅតាមបណ្ដោយរង ឬថ្នាល។ ចន្លោះជួរ ១-១.២ម៉ែត្រ ចន្លោះគុម្ព ៧០-៨០សង្ទីម៉ែត្រ ១គុម្ព ដាំ១ដើម។ ជំរៅរណ្ដៅដែលត្រូវកាប់គឺ ៨-១០ សង្ទីម៉ែត្រ ក្នុងករណីកូន គ្រប់សាបលើថ្នាលផ្ទាល់ គេត្រូវស្រោចទឹកកូនគ្រប់ឱ្យជោគ រយៈពេល ២០-៣០នាទី មុននិងដកយកទៅដាំ ដើម្បីបន្ថយការដាច់ឫស។ កូនត្រប់ត្រូវដកពីពេលព្រឹក បន្ទាប់មកយកវាទៅដាក់ក្នុងឧបករណ៍ដូចជា កញ្ជើ ល្អី កញ្ឆេ។ល។ ស្រោចទឹកអោយជោគ រក្សាទុកនៅក្រោមម្លប់ ធ្វើយ៉ាងណាឱ្យកូនត្រប់មានសភាពរឹងមាំធន់កំដៅថ្ងៃ ទើបយកទៅដាំនៅពេលថ្ងៃរសៀលចាប់ពីម៉ោង ពីរ រហូតដល់ពេលល្ងាចត្រជាក់ ក្រោយពីដាំភ្លាមត្រូវស្រោចទឹកអោយជោគ តាមរណ្ដៅនិមួយៗ។

គ-ការដាក់ជី

ដាក់ទ្រាប់បាត ៖ កំប៉ុស្តិ៍ ១០-១៥តោន/ហិចតា

ជីបំប៉នលើកទី ១ ៖ ក្រោយដាំរយៈពេល ៧-១០ថ្ងៃ

ជីបំប៉នលើកទី ២ ៖ រយៈពេល ៣ អាទិត្យក្រោយដាំដោយយកជីទឹក (លាមកគោ មាន់ ត្រាំជាមួយទឹក រយៈពេល ២០-៣០ថ្ងៃ) យកទៅលាយទឹករួចស្រោច ៧-១០ថ្ងៃម្ដង ជួយអោយត្រប់ចេញផ្កាបានច្រើន។

ឃ-ការស្រោចទឹក

ដំណាំត្រប់គឺមិនត្រូវការទឹកជោគជាំពេកទេ ។

ង-ការដោតចំណារ

ត្រូវដោតចំណារ ក្រោយពេលដាំ ១០-២០ថ្ងៃ ដើម្បីទប់ដើមកុំអោយដួល ។

ច-ការកាត់មែក និងស្លឹកចាស់

-កាត់មែកផ្នែកខាងក្រោមចោលពី ៣-៤មែក

-កាត់ស្លឹកចាស់ផ្នែកខាងក្រោមចេញពី ៨-១០ សន្លឹក ពេលត្រប់មានអាយុ ៥០-៦០ថ្ងៃ។

**ជំងឺសំខាន់ៗ**

ក-ក្រុមជំងឺផ្សិតៈ ជំងឺរលួយកូនត្រប់ ជំងឺអុចស្លឹកពណ៌ត្នោត ជំងឺស្ងួតដើមរលួយឫស...។

**វិធានការការពារៈ** បាចកំបោរសចំនួន ២៥០-៣៥០គ.ក្រ/១ហិកតា ភ្ជួរលប់រយៈពេល ២អាទិត្យ ទើបរៀបចំដីដាំដោយបាញ់ថ្នាំម៉ាណែប (Maneb) ឬ ម៉ង់កូហ្សែប (Mancozeb)ឬ កាប់តាន (Captan)មួយអាទិត្យម្ដងៗ ចាប់តាំងពីសាបរហូតដល់ត្រប់ចេញផ្កា និងផ្លែ។

ខ-ក្រុមជំងឺវីរុសៈ ជម្ងឺដែលកើតបង្កឡើងដោយវីរុសអាចកើតឡើងដោយកំរតីដោយសារការចំលងពីភ្នាក់ងារផ្សេងៗដូចជា មមាចជញ្ជក់ស្លឹក ចៃជញ្ជក់ស្លឹក-ដើម និងរុយស ។

**វិធានការការពារៈ** ដាំពូជធន់ និងកំចាត់សត្វល្អិត ដែលជាភ្នាក់ងារចំលងមេរោគ ។

**សត្វល្អិតចង្រៃ**

ដង្កូវស៊ីរូងដើម ដង្កូវស៊ីរូងផ្លែ ដង្កូវមូរស្លឹក និងកូនដង្កូវរបស់អណ្ដើកមាស១២ចំណុច។

**វិធានការការពារៈ** ជ្រើសរើសពូជធន់ទ្រាំល្អ រៀបចំដីអោយបានត្រឹមត្រូវ ផ្លាស់ប្ដូរមុខដំណាំ ជ្រើសរើសរដូវដាំដុះ ដាំមានចន្លោះជួរ និងគុម្ពបានត្រឹមត្រូវ កាត់រំលួសស្លឹកចោលខ្លះសំអាតស្មៅនៅក្នុងចំការ។

## ៣. ការប្រមូលផល

ពេលប្រមូលផលត្រប់អាចខុសៗគ្នា ទៅតាមប្រភេទពូជរបស់ត្រប់។ ប្រភេទត្រប់ផ្លែខ្លីដូចជា ត្រប់ពងមាន់ ត្រប់ក្រាំងរមាស និងត្រប់សណ្ដាយផ្លែខ្លី គឺចន្លោះពី ៧០-៧៥ ថ្ងៃ ហើយការប្រមូលផលអាចច្រើនលើក អាស្រ័យទៅលើការថែទាំជាពិសេសដោយមានការកាត់មែក និងស្លឹកចាស់ចោល ដាក់ជីបន្ថែម និងស្រោចទឹក។ ចំពោះត្រប់វាមាន ទិន្នផលជាមធ្យម គឺ ត្រប់ក្រាំងរមាស ១១-១៣តោន ក្នុង១ហិកតា ត្រប់ពងមាន់ ចន្លោះពី ៨-១០តោន ក្នុង១ហិកតា រីឯត្រប់សណ្ដាយផ្លែខ្លី ន្លោះពី ៧-៩តោន ក្នុង១ហិកតា។